Minnesota Department of Education

Division of Compliance and Assistance

# Alternative Dispute Resolution (ADR)

## ***ប្រសិន***បើអ្នកមិនរសាយចិត្តអំពីការអប់រំរបស់កូនអ្នក មានវិធីមួយចំនួនដែលអាចដោះស្រាយបាន ។

ហៅទូរស័ព្ទមកជួបជាមួយនឹងនាយកកម្មវិធីអប់រំពិសេសប្រចាំស្រុករបស់អ្នក ។ និយាយប្រាប់គាត់អំពីក្តីព្រួយបារម្ភរបស់អ្នក ។ អ្នកអាចរកមើលបញ្ជីឈ្មោះនាយកកម្មវិធីអប់រំពិសេសពីគេហទំព័រ ។

កន្លែងផ្សេងទៀតដែលអ្នកអាចហៅរកជំនួយបានគឺសេវាកម្មការដោះស្រាយជម្លោះក្រៅតុលាការរបស់នាយកដ្ឋានអប់រំប្រចាំរដ្ឋមីណេសូតា (Minnesota Department of Education’s Alternative Dispute Resolution-ADR) សម្រាប់ការអប់រំពិសេស ។

សេវាកម្ម ADR ជួយគ្រួសារ សាលា និងភ្នាក់ងារឲ្យបានជួបគ្នានិយាយគ្នា និងដោះស្រាយពីការយល់ឃើញខុសគ្នា ដោយធ្វើការប្រជុំសម្រុះសម្រួល ឬសម្របសម្រួលការប្រជុំកម្មវិធីអប់រំតម្រូវតាមលក្ខណៈបុគ្គល (Individualized Education Program-IEP) ។

## ***តើខ្ញុំ***គួរជ្រើសរើសយកវិធីមួយណា?

សូមសាកល្បងវិធីការសម្រុះសម្រួល បើអ្នកត្រូវការពេលនិយាយបែបធូរស្រាល ផ្សះផ្សារទំនាក់ទំនង រកឲ្យឃើញនូវបញ្ហា និងរកដំណោះស្រាយថ្មី ។ បុគ្គលទីបីដែលជាមនុស្សកណ្តាល អ្នកសម្រុះសម្រួល នឹងជួយអ្នកឲ្យបានយល់អំពីទស្សនៈរបស់គ្នាទៅវិញទៅមក និងស្វែងរកការព្រមព្រៀងគ្នាមួយ ។

សូមសាកល្បងការប្រជុំសម្របសម្រួល IEP ប្រសិនបើអ្នកនិងសាលាកំពុងតែមានបញ្ហាក្នុងការបង្កើតផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល (Individualized Education Program-IEP) ឲ្យកូនរបស់អ្នក ។ បុគ្គលទីបីដែលជាមនុស្សកណ្តាល អ្នកសម្របសម្រួល នឹងដឹកនាំការពិភាក្សាឆ្លងតាមដំណើរការ IEP ជាមួយនឹងក្រុមរបស់កូនអ្នក និងជួយដោះស្រាយចំពោះចំណុចណាដែលមិនយល់ស្របគ្នា ក្នុងពេលជាមួយគ្នា ។

## ***ព័ត៌មាន***បន្ថែមអំពីការសម្រុះសម្រួល ឬការប្រជុំសម្របសម្រួល IEP ៖

- វិធីទាំងពីរនេះ សុទ្ធតែធ្វើឡើងដោយមិនបាច់បង់ប្រាក់ឡើយ!
- អ្នកសម្រុះសម្រួល ឬអ្នកសម្របសម្រួល ស្រ័យទាក់ទងជាមួយភាគីទាំងពីរដោយក្តីគោរព ។
- អ្នក និងសាលាធ្វើសេចក្តីសម្រេចចិត្តរួមគ្នា ។
- ភាគច្រើន អ្នកយល់ព្រមជាមួយគ្នា អំពីវិធីដោះស្រាយពីតម្រូវការរបស់កូនអ្នក ។

## ***ចុះ***បើកូនរបស់ខ្ញុំមានផែនការអប់រំខុសពីផែនការ IEPត្រូវធ្វើយ៉ាងណាដែរ?

អ្នកក៏អាចស្នើសុំឲ្យមានការប្រជុំសម្របសម្រួល ឬការសម្រុះសម្រួល ប្រសិនបើអ្នកមានផែនការផ្តល់សេវាកម្មតម្រូវតាមលក្ខណៈគ្រួសារ (individualized family service plan-IFSP) ឬមួយបើអ្នកមានផែនការអន្តរាគមន៍អន្តរភ្នាក់ងារតម្រូវតាមលក្ខណៈបុគ្គល (individualized interagency intervention plan-IIIP) សម្រាប់កូនតូចរបស់អ្នក ដោយសារអ្នកត្រូវធ្វើការជាមួយភ្នាក់ងារដទៃបន្ថែមពីលើសាលារបស់កូនអ្នក ។

## ***ចុះ***បន្ទាប់មកទៀតខ្ញុំត្រូវធ្វើអ្វី?

ហៅទូរស័ព្ទមកជួបយើងខ្ញុំ ។ យើងខ្ញុំអាចប្រាប់ឲ្យអ្នកបានដឹងបន្ថែមអំពីការសម្រុះសម្រួល ឬការប្រជុំសម្របសម្រួល និងផ្ញើឲ្យអ្នកនូវបែបបទស្នើសុំធ្វើការប្រជុំណាមួយ ។

**651-582-8222** ឬលេខហៅមិនបាច់បង់ប្រាក់

**866-466-7367**

**http://education.state.mn.us**